GAIN
Growth and Inclusivity in Cambodia's Higher Education

Co-funded by the European Union

ឧបករណ៍វិភាគទិន្នន័យ GAIN

របាយការណ៍ប្រចាំឆ្នាំ ២០២៤-២០២៥

កម្មវិធីកសាងសមត្ថភាព Erasmus+ ERASMUS-EDU2024-CHBE-STRAND-3
គម្រោងលេខ 101178043

របាយការណ៍ប្រចាំឆ្នាំ ២០២៤-២០២៥ នៃឧបករណ៍វិភាគទិន្នន័យគម្រោងGAIN។ រៀបចំឡើងក្នុងក្របខ័ណ្ឌនៃគម្រោង GAIN (កំណើននិងបរិយាបន្នអប់រំក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា) ដែលទទួលមូលនិធិរួមពីកម្មវិធីកសាងសមត្ថភាព Erasmus+ ERASMUS-EDU2024-CBHE-STRAND-3 (គម្រោងលេខ 101178043)។
រៀបរៀងដោយ ReadLab ក្រោមកញ្ចប់ការងារទី២ (ផែនការសកម្មភាពប្រកបដោយចីរភាព) លទ្ធផលទី2.2 (ឧបករណ៍វិភាគទិន្នន័យ)។

ព័ត៌មាន ឯកសារ និងតួលេខក្នុងលទ្ធផលនេះត្រូវបានសរសេរនិងរៀបរៀងដោយសមាជិកដៃគូគម្រោង GAIN ក្រោមកិច្ចព្រមព្រៀងពីជំនួយ EC Erasmus-Edu2024-CBHE-strand-3 គម្រោងលេខ 101178043 ដែលរាល់ទិន្នន័យនិងពាក្យពេចន៍ដែលបានបង្ហាញមិនបានឆ្លុះបញ្ចាំងឬស្ថិតនៅក្រោមទំនួលខុសត្រូវរបស់សហភាពអឺរ៉ុបឬទីភ្នាក់ងារប្រតិបត្តិការអប់រំ និងវប្បធម៌អឺរ៉ុប (EACEA)ទេ។
គណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលមានក្នុងឯកសារនេះឡើយ។

លទ្ធផលនេះមានផ្ទុកស្នាដៃដើមដែលមិនទាន់បោះពុម្ពផ្សាយលើកលែងតែកន្លែងដែលត្រូវបានបង្ហាញច្បាស់លាស់។ ពាក្យពេចន៍ដែលត្រូវបានដកស្រង់ពីស្នាដៃនិពន្ធដែលបានបោះពុម្ពពីមុនៗ ត្រូវបានបង្ហាញជាឯកសារយោងនិងសេចក្តីថ្លែងអំណរគុណយ៉ាងសមស្រប។ ការផលិតឡើងវិញនូវខ្លឹមសារនេះត្រូវបានអនុញ្ញាតដោយមានការទទួលស្គាល់ជាឯកសារយោង និងបញ្ជាក់ប្រភពដើម។ ។
ការផ្សព្វផ្សាយលទ្ធផលនានា គឺឆ្លុះបញ្ចាំងតែពីទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយគណៈកម្មការអឺរ៉ុប (European Commission) មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងឯកសារនេះក្នុងគោលបំណងណាមួយឡើយ។ ការទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ គឺស្ថិតនៅលើអ្នកនិពន្ធ។

របាយការណ៍នេះស្ថិតក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution 4.0 International License (CC BY 4.0); ច្បាប់ចម្លងមាននៅ៖ https://creativecommons.org/licenses/by/4.0/

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

មាតិកា

សេចក្តីថ្លែងអំណរគុណ 6

សេចក្តីផ្តើម 7

វិធីសាស្រ្តប្រមូលទិន្នន័យ 8

លទ្ធផលតាមស្ថាប័ន 13

ការវិភាគបែបប្រៀបធៀប 19

ការឆ្លើយតបរបស់គម្រោង GAIN 23

សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ 25

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

បញ្ជីតារាង

តារាង 1. សេចក្តីរាយការណ៍ទិន្នន័យបរិមាណវិស័យ៖ ដែនសូចនាករទាំងប្រាំពីរ10

តារាង 2. ការស្ទង់មតិពីការពេញចិត្តរបស់និស្សិត៖ ការបែងចែកចម្លើយតាមស្ថាប័ន11

តារាង 3. ការចូលរួមរបស់គ្រឹះស្ថានឧត្តមសិក្សានានា៖ ឆ្នាំសិក្សា ២០២៤-២០២៥12

តារាង 4. ITC: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥.. 13

តារាង 5. RUPP: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥................................... 15

តារាង 6. WU: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥.. 16

តារាង 7. PPIU: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥..................................... 18

បញ្ជីរូបភាព

រូបភាព 1. ក្របខ័ណ្ឌវិធីសាស្ត្រស្រាវជ្រាវចម្រុះ..8

រូបភាព 2. សក្ខីកម្មរបស់និស្សិត – ITC.. 12

រូបភាព 3. សក្ខីកម្មរបស់និស្សិត – RUPP.. 13

រូបភាព 4. សក្ខីកម្មរបស់និស្សិត – WU.. 13

រូបភាព 5. សក្ខីកម្មរបស់និស្សិត – USEA.. 14

រូបភាព 6. សក្ខីកម្មរបស់និស្សិត – PPIU..18

រូបភាព 7. ទិដ្ឋភាពសង្ខេបនៃមូលដ្ឋានគោល ២០២៤-២០២៥.................................. 16

រូបភាព 8. ការប្រៀបធៀបរវាងស្ថាប័ននិងស្ថាប័ន៖ សូចនាករសំខាន់ៗ.............. 18

រូបភាព 9. ការចុះឈ្មោះនិស្សិតនិងអត្រាពិការភាពដែលបានប្រកាសតាមគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ឆ្នាំសិក្សា ២០២៤-២០២៥.. 20

រូបភាព 10. ការឆ្លើយតបរបស់គម្រោង GAIN.. 22

រូបភាព 11. លទ្ធផលស្ទង់មតិការពេញចិត្តរបស់និស្សិតតាមស្ថាប័ន ឆ្នាំសិក្សា ២០២៤-២០២៥...26

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

បញ្ជីអក្សរកាត់

AA	អនុលោមតាមកម្រិតស្តង់ដា AA នៃគោលការណ៍ណែនាំស្តីពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់មាតិកាគេហទំព័រ
ASEAN	សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
AT	បច្ចេកវិទ្យាជំនួយ
CESIE	មជ្ឈមណ្ឌលអឺរ៉ុបសម្រាប់ការសិក្សា និងគំនិតផ្តួចផ្តើម
CRPD	អនុសញ្ញាស្តីពីសិទ្ធិជនពិការ
ECTS	ប្រព័ន្ធផ្ទេរ និងបូកសរុបក្រេឌីតអឺរ៉ុប
GAIN	កំណើន និងបរិយាបន្នអប់រំក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
GDPR	បទប្បញ្ញត្តិទូទៅស្តីពីការការពារទិន្នន័យ
HEI	គ្រឹះស្ថានឧត្តមសិក្សា
IIC	មជ្ឈមណ្ឌលបរិយាបន្ន
ITC	វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
LMS	ប្រព័ន្ធគ្រប់គ្រងការសិក្សា
MoEYS	ក្រសួងអប់រំ យុវជន និងកីឡា
OER	ធនធានអប់រំបើកចំហ
PPIU	សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
PWD	ជនមានពិការភាព
RUPP	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
SDG	គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
UN	អង្គការសហប្រជាជាតិ
USEA	សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍
WCAG	គោលការណ៍ណែនាំស្តីពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់មាតិកាគេហទំព័រ
WP	កញ្ចប់ការងារ
WU	សាកលវិទ្យាល័យវេស្ទើន

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សេចក្ដីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបរៀងឡើងដោយក្រុមការងាររបស់ ReadLab ក្រោមក្របខណ្ឌនិងក្នុងនាមស្ថាប័នដៃគូគម្រោងGAIN។ ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកចូលរួមចំណែកដូចខាងក្រោម៖

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ក្នុងនាមជាអ្នកសម្របសម្រួលគម្រោង និងជាអ្នកគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការឧបករណ៍វិភាគទិន្នន័យនេះ និងក្រសួងអប់រំ យុវជន និងកីឡា (MoEYS) សម្រាប់ការត្រួតពិនិត្យបច្ចេកទេស និងការប្តេជ្ញាចិត្តចំពោះគោលនយោបាយបរិយាបន្នអប់រំតាមគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងគ្រឹះស្ថានឧត្តមសិក្សាដៃគូចំនួនប្រាំដែលរួមមានវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍, សាកលវិទ្យាល័យវេស្ទើន និង សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ដែលបានចូលរួមចងក្រងទិន្នន័យរបស់ស្ថាប័នដើម្បីបង្កើតជាមូលដ្ឋានគោលនៃរបាយការណ៍នេះ។

និស្សិតមានពិការភាពចំនួន ៤០នាក់ នៅទូទាំងគ្រឹះស្ថានទាំង៥នេះ បានឆ្លើយតបការស្ទង់មតិស្តីពីការពេញចិត្តទៅលើសេវាកម្មគាំទ្ររបស់គ្រឹះស្ថានអប់រំឧត្តមសិក្សា និងចែករំលែកបទពិសោធន៍ឧបសគ្គនានា និងសេចក្តីស្នើសុំទៅដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងនាមនិស្សិតពិការភាព។ សំឡេងរបស់ពួកគេជាចំណុចកណ្តាលនៃរបាយការណ៍នេះ។

ស្ថានប័នដៃគូគម្រោងនៅអឺរ៉ុប រួមមានទាំងសាកលវិទ្យាល័យ Patras សាកលវិទ្យាល័យ Rome Tor Vergata និងCESIE សម្រាប់ការរួមចំណែកក្នុងការរៀបរៀងវិធីសាស្ត្រអនុវត្តគម្រោង និងការធានាគុណភាពរបស់គម្រោង។

របាយការណ៍នេះ គឺជារបាយការណ៍ប្រចាំឆ្នាំលើកទីមួយរបស់ ឧបករណ៍វិភាគទិន្នន័យគម្រោង GAIN (GAIN Data Analysis Tool) ប្រចាំឆ្នាំ 2024-2025។ របាយការណ៍នេះបានបង្កើតនូវទិន្នន័យមូលដ្ឋាន (Baseline) ដែលនឹងត្រូវប្រើជាចំណុចយោងសម្រាប់តាមដានវឌ្ឍនភាពនិងជាគ្រឹះសម្រាប់របាយការណ៍ចំនួន៣បន្តបន្ទាប់ទៀត។ ឧបករណ៍វិភាគទិន្នន័យនេះនឹងត្រូវគ្រប់គ្រងប្រព័ន្ធដំណើរការបច្ចេកទេសដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានិងគ្រប់គ្រងប្រតិបត្តិការទិន្នន័យដោយក្រសួងអប់រំ យុវជន និងកីឡា។ ឧបករណ៍នេះត្រូវបានរចនាឡើងដើម្បីគាំទ្រការអភិវឌ្ឍគោលនយោបាយជាក់លាក់សម្រាប់បរិយាបន្នអប់រំក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។

ខែកញ្ញា 2026

និពន្ធ និងបោះពុម្ពផ្សាយដោយ ReadLab P.C.

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សេចក្តីផ្តើម

ជនមានពិការភាពនៅតែស្ថិតក្នុងចំណោមក្រុមដែលមានវត្តមាននិងការចូលរួមតិចតួចបំផុតនៅក្នុងការអប់រំឧត្តមសិក្សានៅកម្ពុជា។ ទោះបីជាក្របខ័ណ្ឌគោលនយោបាយជាតិរួមទាំងផែនទីចង្អុលបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជា 2030 (Cambodian Higher Education Roadmap 2030) និងផែនការមេ (ASEAN Enabling Masterplan 2025) បានបង្ហាញយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តបង្កើតឲ្យមានការអប់រំប្រកបដោយសមធម៌សម្រាប់អ្នកសិក្សាទាំងអស់ គ្រឹះស្ថានឧត្តមសិក្សានានានៅតែខ្វះប្រព័ន្ធទិន្នន័យដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដើម្បីតាមដានស្ថានភាពជាក់ស្តែងនិងកំណត់អត្តសញ្ញាណចន្លោះខ្វះខាតដែលមាននៅក្នុងស្ថានប័នរបស់ខ្លួន។

ឧបករណ៍វិភាគទិន្នន័យរបស់គម្រោង GAIN នេះត្រូវបានបង្កើតឡើងដើម្បីឲ្យស្ថាប័ននីមួយៗអាចស្វែងយល់ដឹងពីភាពចន្លោះប្រហោងទាំងនោះ។ ឧបរណ៍នេះជាវេទិកាមួយដែលបកប្រែជាពីរភាសា (អង់គ្លេស និងខ្មែរ) សម្រាប់ប្រមូល វិភាគ និងរាយការណ៍ទិន្នន័យស្តីពីបរិយាបន្នអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាសម្រាប់និស្សិតមានពិការភាព ដោយរួមបញ្ចូលសូចនាករបែបបរិមាណវិស័យជាមួយនិងទិន្នន័យបែបគុណវិស័យដែលទទួលបានពីបទពិសោធន៍ផ្ទាល់របស់និស្សិត។
ឧបករណ៍នេះត្រូវបានរចនាឡើងដើម្បីគាំទ្រដល់ការសម្រេចចិត្តទាំងកម្រិតស្ថាប័ននិងថ្នាក់ជាតិដោយផ្អែកលើភស្តុតាងជាក់លាក់។ ឧបរកណ៍នេះត្រូវបានគ្រប់គ្រងប្រពន្ធ័បច្ចេកទេសដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងគ្រប់គ្រងប្រតិបត្តិការទិន្នន័យដោយក្រសួងអប់រំ យុវជន និងកីឡា ។

របាយការណ៍ប្រចាំឆ្នាំនេះគឺជារបាយការណ៍ទីមួយសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ ក្នុងចំណោមរបាយការណ៍ចំនួន៥ ដែលនឹងគ្រោងបោះផ្សាយបន្តបន្ទាប់ទៀត។ របាយការណ៍នេះផ្អែកលើទិន្នន័យពីគ្រឹះស្ថានដៃគូចំនួន៥ និងពីការស្ទង់មតិពីនិស្សិតដែលមានពិការភាពចំនួន ៤០នាក់ ស្តីពីការពេញចិត្តរបស់ពួកគេទៅលើប្រព័ន្ធគាំទ្ររបស់សាកលវិទ្យាល័យចំពោះនិស្សិតពិការភាព ដើម្បីបង្កើតទិន្នន័យមូលដ្ឋាន ដែលនឹងត្រូវប្រើសម្រាប់វាស់វែងវឌ្ឍនភាពនាពេលអនាគត។ របាយការណ៍នេះត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធដូចខាងក្រោម៖ ជំពូកទី២ ពិពណ៍នាអំពីវិធីសាស្ត្រប្រមូលទិន្នន័យ, ជំពូកទី៣ បង្ហាញពីការរកឃើញសម្រាប់ស្ថាប័ននីមួយៗ, ជំពូកទី៤ ផ្តល់ការវិភាគដោយប្រៀបធៀបជាមួយនឹងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។ ជំពូកទី៥ គូសបង្ហាញពីការឆ្លើយតបរបស់គម្រោង GAIN ចំពោះរកឃើញទាំងនេះនិងជំពូកទី៦ បង្ហាញសេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់។

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

វិធីសាស្ត្រប្រមូលទិន្នន័យ ក្របខ័ណ្ឌវិធីសាស្ត្រ

ក◌ារសិក្សាស្រាវជ្រាវនេះអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះដោយរួមបញ្ចូលគ្នាការប្រមូលទិន្នន័យពីស្ថាប័នតាមបែបគុណវិស័យនិងបរិមាណវិស័យពីនិស្សិតមានពិការភាព។ ការរៀបរៀងវិធីសាស្ត្រនេះអាចបង្ហាញទិន្នន័យពីប្រភពផ្សេងៗ ឬត្រីកោណមាត្រទិន្នន័យ (data triangulation) ដោយផ្ទៀងផ្ទាត់និងប្រៀបធៀបលទ្ធផលពីកំណត់ត្រារបស់ស្ថាប័ន ជាមួយបទពិសោធន៍ជាក់ស្តែងរបស់និស្សិតមានពិការភាព។ វិធីសាស្ត្រនេះមិនត្រឹមតែបង្ហាញនូវតួរលេខដែលជាសូចនាករដែលអាចវាស់វែងបានសម្រាប់ការត្រួតពិនិត្យគោលនយោបាយប៉ុណ្ណោះទេ តែក៏បានបង្ហាញពីបរិបទស៊ីជម្រៅក្នុងការស្វែងយល់បន្ថែមពីឧបសគ្គនានាដែលនិស្សិតពិការភាពជួបប្រទះផងដែរ។

ការប្រមូលទិន្នន័យត្រូវបានរៀបចំឡើងជាសម្ព័ន្ធដោយប្រើប្រាស់ឧបករណ៍សំខាន់ៗពីរដែលមានលក្ខណៈបំពេញគ្នា។ ឧបករណ៍ទាំងពីរត្រូវបានរៀបចំដោយ ReadLab និង ដាក់ពង្រាយនូវទូទាំងគ្រឹះស្ថានឧត្តមសិក្សាទាំង៥៖

- **ឧបករណ៍ប្រមូលទិន្នន័យបរិមាណវិស័យ៖** សន្លឹកកិច្ចការដែលមានស្តង់ដារត្រូវបានបំពេញដោយគ្រឹះស្ថានឧត្តមសិក្សានីមួយៗ គ្រប់ដណ្តប់ដែនសូចនាករចំនួន៧។
- **ឧបករណ៍ប្រមូលទិន្នន័យគុណវិស័យ៖** កម្រងសំណួរដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ត្រូវបានផ្តល់ឱ្យនិស្សិតមានពិការភាព ដោយរួមបញ្ចូលសំណួរបែបបិទដែលប្រើមាត្រដ្ឋាន Likert និងសំណួរបែបបើកចំហដែលអនុញ្ញាតឱ្យនិស្សិតរៀបរាប់អំពីបទពិសោធន៍ និងមតិយោបល់របស់ពួកគេបានទូលំទូលាយ។



រូបភាព១. ក្របខ័ណ្ឌវិធីសាស្ត្រចម្រុះ

ការប្រមូលទិន្នន័យបរិមាណវិស័យ

គ្រឹះស្ថានឧត្តមសិក្សានីមួយៗបានជ្រើសរើសអ្នកតំណាង១រូប ដើម្បីបំពេញសន្លឹកកិច្ចការដោយផ្អែកទៅលើកំណត់ត្រារដ្ឋបាល ប្រព័ន្ធទិន្នន័យដែលបានរក្សាទុក និងកំណត់ត្រាហិរញ្ញវត្ថុរបស់ស្ថាប័ន។ ទិន្នន័យបរិមាណ

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

វិស័យត្រូវបានប្រមូលពីខែមេសាដល់ ខែសីហា ឆ្នាំ២០២៦ សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥។ ទិន្នន័យត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធដែលបានកំណត់ទុកនិងគណនាដោយស្វ័យប្រវត្តិដើម្បីជានាឲ្យបាននូវភាពស៊ីសង្វាក់គ្នារបស់ទិន្នន័យប្រកបដោយគុណភាព។ របាយការណ៍នឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ដែលសរុបរួមមានបួន(៤) របាយការណ៍៖ របាយការណ៍ដំបូងក្នុងឆ្នាំសិក្សា២០២៤-២០២៥ និងបន្តបន្ទាប់ក្នុងឆ្នាំ២០២៥-២០២៦, ២០២៦-២០២៧និង ២០២៧-២០២៧។

Co-funded by
the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

ដែនវិស័យ	សូចនាករ
១. ការចូលរួម និងការទទួលបានការអប់រំ	ចំនួននិស្សិតចុះឈ្មោះសរុប និស្សិតមានពិការភាពដោយបែងចែកតាមប្រភេទពិការភាព និស្សិតចូលថ្មី និងនិស្សិតមានពិការភាពចូលថ្មី។
២. ការផ្តល់ជូនការសម្របសម្រួល	សំណើដែលបានទទួល/អនុម័ត/អនុវត្ត ប្រភេទការផ្តល់សេវាកម្មសម្របសម្រួល និងរយៈពេលនៃការផ្តល់សេវាកម្មសម្របសម្រួល។
៣. ការបន្ត និងការបញ្ចប់ការសិក្សា	អត្រាបោះបង់ការសិក្សា (និស្សិតទាំងអស់/និស្សិតមានពិការភាព) អត្រាបញ្ចប់ការសិក្សា និងការបន្តការសិក្សាពីឆ្នាំមួយទៅឆ្នាំមួយ។
៤. ភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល	គេហទំព័រដែលបានធ្វើសវនកម្ម/អនុលោមតាម WCAG ម៉ូឌុល LMS និងឯកសារសិក្សាអាចទាញយកប្រើប្រាស់បាន។
៥. ការប្រើប្រាស់សេវាគាំទ្រ	និស្សិតមានពិការភាពដែលបានចុះឈ្មោះទទួលយកសេវាកម្មគាំទ្រ ការប្រឹក្សា ការប្រើប្រាស់ឧបករណ៍ជំនួយ ការប្រឹក្សាណែនាំពីមិត្តរួមជំនាន់ និងការគាំទ្រហិរញ្ញវត្ថុ។
៦. ការបណ្តុះបណ្តាលបុគ្គលិក	ចំនួនបុគ្គលិកសិក្សា/បុគ្គលិករដ្ឋបាល និងបុគ្គលិកដែលបានទទួលបានការបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់សិស្សមានពិការភាព /បុគ្គលិកយល់ដឹងពីពិការភាព។
៧. ការបែងចែកមូលនិធិ	កញ្ចប់ថវិកាសរុប កញ្ចប់ថវិកាសម្រាប់សេវាជនពិការ កញ្ចប់ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ជំនួយ សម្រាប់ការបណ្តុះបណ្តាល និងសម្រាប់អាហារូបករណ៍។

តារាង១. ការរាយការណ៍ទិន្នន័យបរិមាណវិស័យ៖ ដែនសូចនាករទាំងប្រាំពីរ

ការប្រមូលទិន្នន័យគុណវិស័យ

ការស្ទង់មតិអំពីការពេញចិត្តរបស់និស្សិតមានពិការភាពក្នុងការប្រើប្រាស់សេវាកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា គឺជាកម្រងសំណួរដែលមានរចនាសម្ព័ន្ធច្បាស់លាស់ (structured questionnaire) នឹងត្រូវបានផ្ញើជូននិស្សិតមានពិការភាពដែលកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាដៃគូចំនួនប៥។ ការស្ទង់មតិនេះត្រូវបានរៀបចំឡើងដោយ ReadLab និងត្រូវអនុវត្តក្នុងអំឡុងខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៦។

ការស្ទង់មតិមានកម្រងសំណួរចំនួន ២៥ បែងចែកជា 5 ប្រធានបទ៖

- **ប្រជាសាស្ត្រ និងការកំណត់អត្តសញ្ញាណពិការភាព** (គ្រឹះស្ថានឧត្តមសិក្សា ឆ្នាំសិក្សា ប្រភេទពិការភាព)
- **ការយល់ឃើញអំពីការចូលប្រើប្រាស់ធនធានរបស់គ្រឹះស្ថាន** (ទីតាំងរូបវន្ត សម្ភារៈឌីជីថល ឧបករណ៍ឬបច្ចេកវិទ្យាជំនួយផ្សេងៗ)
- **តម្លាភាព និងការគាំទ្ររបស់គ្រឹះស្ថាន** (ការផ្តល់សេវាកម្មដែលមិនតម្លាភាពឬមិនយុត្តិធម៌ ការប្តេជ្ញាចិត្តរបស់ស្ថាប័ន សេរីភាពក្នុងការលើកឡើងពីបញ្ហា)
- **សេវាកម្មគាំទ្រ** (ការយល់ដឹងអំពីសេវាកម្ម កម្រិតនៃការពេញចិត្ត សេវាកម្មដែលបានប្រើប្រាស់ ភាពងាយស្រួលក្នុងការទទួលបានសេវាកម្ម ការយល់ដឹងរបស់បុគ្គលិកអំពីពិការភាព)
- **ការពេញចិត្តជារួម និងការឆ្លើយតបដោយបើកចំហ** (បទពិសោធន៍ទូទៅ បទពិសោធន៍ជាក់លាក់ ការផ្លាស់ប្តូរដែលនិស្សិតចង់បាន)

ការស្ទង់មតិនេះត្រូវបានរៀបចំជាពីរភាសា គឺភាសាអង់គ្លេស និងភាសាខ្មែរ។ អ្នកឆ្លើយតបបានផ្តល់ការយល់ព្រមយ៉ាងច្បាស់លាស់ ដែលអនុលោមតាមតម្រូវការរបស់ GDPR សម្រាប់ការដំណើរការទិន្នន័យ។ ចំនួនការឆ្លើយតបសរុបមាន៤០នាក់ ដែលក្នុងនោះ ៣៧នាក់ បានផ្តល់ការយល់ព្រមឱ្យប្រើប្រាស់ទិន្នន័យ។ អ្នកឆ្លើយតបចំនួន ៣ នាក់ផ្សេងទៀត ដែលមិនបានផ្តល់ការយល់ព្រមឲ្យប្រើប្រាស់ទិន្នន័យ ត្រូវបានដកចេញពីការវិភាគទិន្នន័យតាមសំណួរបើកចំហ ប៉ុន្តែត្រូវបានរាប់បញ្ចូលក្នុងស្ថិតិសរុបនិងត្រូវបានរក្សាទុកជាការសម្ងាត់។

HEI	ចម្លើយ	បានផ្តល់ការយល់ព្រម
ITC	10	10

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

HEI	ចម្លើយ	បានផ្តល់ការយល់ព្រម
RUPP	7	6
WU	16	14
USEA	3	3
PPIU	4	4
សរុប	**40**	**37**

តារាង២. ការស្ទង់មតិពីការពេញចិត្តរបស់និស្សិត៖ ការបែងចែកចម្លើយតាមស្ថាប័ន

ត្រីកោណមាត្រទិន្នន័យ (Data Triangulation)

ត្រីកោណមាត្រទិន្នន័យ ឬទិន្នន័យប្រៀបធៀប ត្រូវបានអនុវត្តតាមរយៈការផ្ទៀងផ្ទាត់ និងប្រៀបធៀបទិន្នន័យសូចនាករបរិមាណវិស័យរបស់ស្ថាប័នជាមួយនិងការយល់ឃើញរបស់និស្សិតដែលមានលក្ខណៈគុណវិស័យនៅក្នុងវិមាត្រដូចគ្នា។ ឧទាហរណ៍ របាយការណ៍របស់គ្រឹះស្ថានឧត្តមសិក្សាដែលបង្ហាញពីចំនួនសម្ភារៈសិក្សាដែលអាចចូលឬទាញយកប្រើប្រាស់បាន (ទិន្នន័យបរិមាណវិស័យ) នឹងត្រូវបានប្រៀបធៀបជាមួយការវាយតម្លៃរបស់និស្សិតអំពីភាពងាយស្រួលក្នុងការចូលឬទាញយកមកប្រើប្រាស់សម្ភារៈឌីជីថលទាំងនោះ(ទិន្នន័យគុណវិស័យ)។ ដូចគ្នានេះដែរ ហេដ្ឋារចនាសម្ព័ន្ធនៃសេវាគាំទ្រនិស្សិតពិការភាពដែលគ្រឹះស្ថានបានរាយការណ៍ នឹងត្រូវបានប្រៀបធៀប ជាមួយកម្រិតនៃការយល់ដឹងនិងអត្រានៃការពេញចិត្តរបស់និស្សិតទៅលើសេវាកម្មគាំទ្រទាំងនោះរបស់គ្រឹះស្ថាន។

វិធីសាស្ត្រនេះមិនត្រឹមតែអាចបង្ហាញពីរបាយការណ៍ស្តីពីសេវាគាំទ្ររបស់គ្រឹស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចកំណត់បានថា តើនិស្សិតមានពិការភាព បានយល់ដឹងអំពី និងទទួលបានបទពិសោធន៍ជាក់ស្តែងពីសេវាកម្ម និងការគាំទ្រទាំងនោះឬអត់។ ភាពខុសគ្នារវាងទិន្នន័យទាំងពីរនេះ ឧទាហរណ៍ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) មានការិយាល័យឧទ្ទិសគាំទ្រដែលមានទំហំធំ និងមាននិស្សិតមានពិការភាពចុះឈ្មោះចំនួន ១១៣ នាក់ ប៉ុន្តែទទួលបានពិន្ទុទាបបំផុតស្តីពីការយល់ដឹងអំពីសេវាកម្មគាំទ្ររបស់គ្រឹះស្ថាន (២.៧១/៥) ដែលនេះគឺជារបកគំហើញសំខាន់មួយ ដែលអាចបង្ហាញពីគម្លាតក្នុងការទំនាក់ទំនង ឬការអនុវត្តសេវាគាំទ្រទៅដល់និស្សិតដែលមានពិការភាព។

អក្សរកាត់	ឈ្មោះពេញ	ទីក្រុង	ប្រភេទ	ចំនួនចុះឈ្មោះ
ITC	វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា	ភ្នំពេញ	រដ្ឋ	7,432
RUPP	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	ភ្នំពេញ	រដ្ឋ	29,098
WU	សាកលវិទ្យាល័យវេស្ទើន	ភ្នំពេញ	ឯកជន	2,348
USEA	សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍	សៀមរាប	ឯកជន	1,708
PPIU	សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ	ភ្នំពេញ	ឯកជន	2,244

តារាង៣. គ្រឹះស្ថាបឧត្តមសិក្សាចូលរួម៖ ឆ្នាំសិក្សា ២០២៤-២០២៥

ដែនកំណត់

នេះជាវដ្តដំបូងនៃការប្រមូលទិន្នន័យហើយមានចំនុចខ្វះខាតមួយចំនួនដែលត្រូវបានកត់សម្គាល់។ គ្រឹះស្ថានទាំងអស់បានបំពេញទិន្នន័យសម្រាប់ដែនសូចនាករគ្រប់ផ្នែកនីមួយៗឡើយ៖ សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ (USEA) ផ្តល់ទិន្នន័យចំនួននិស្សិតចុះឈ្មោះសរុប ប៉ុន្តែមិនបានបង្ហាញទិន្នន័យបែងចែកពិការភាពនិងភាគច្រើននៃទិន្នន័យស្តីពីសេវាកម្មសម្របសម្រួលដល់និស្សិតមានពិការភាពមិនត្រូវបានបង្ហាញ។ មានតែសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និង សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ(PPIU) ប៉ុណ្ណោះដែលបានរាយការណ៍មួយផ្នែកពីទិន្នន័យទាក់ទងជាមួយភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់គ្រឹះស្ថាន។ ការដែលនិស្សិតមិនប្រកាសអំពីស្ថានភាពពិការភាពរបស់ខ្លួន (Under-declaration of disability) គឺជាបញ្ហាប្រឈមមួយដែលត្រូវបានកត់ត្រាយ៉ាងទូលំទូលាយនៅក្នុងបរិបទប្រទេសកម្ពុជា។ មានន័យថានិស្សិតមានពិការភាពដែលបានប្រកាសចំនួន ១២៦

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

នាក់ មិនបានឆ្លុះបញ្ចាំងពីចំនួនពិតប្រាកដនៃនិស្សិតមានពិការភាពដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាដៃគូចំនួន៥នោះទេ។

ការស្ទង់មតិបែបគុណវិស័យទទួលបានការឆ្លើយតបចំនួន៤០នាក់ គឺជាចំនួនសំណាកគំរូសមស្របសម្រាប់ទទួលបានការយល់ដឹងអំពីនិន្នាការ ប៉ុន្តែមិនមែនជាគំរូដែលអាចគាំទ្រដល់ការធ្វើសេចក្តីសន្និដ្ឋានទូទៅបានទេ។ ចំនួនអ្នកឆ្លើយតបខ្ពស់ជាងគេរបស់សាកលវិទ្យាល័យវេស្ទើន (WU), 16នាក់ ឆ្លុះបញ្ចាំងពីការផ្សព្វផ្សាយ និងទំនាក់ទំនងយ៉ាងសកម្មរបស់គ្រឹះស្ថានជាមួយនិស្សិតមានពិការភាព ជាជាងបង្ហាញពីចំនួននិស្សិតសរុបដែលមានពិការភាព។ លទ្ធផលទាំងអស់គួរត្រូវបានបកស្រាយក្នុងន័យជាទិន្នន័យមូលដ្ឋាន (Baseline) ដែលនឹងត្រូវសិក្សាឲ្យកាន់តែស៊ីជម្រៅតាមរយៈវដ្តនៃការប្រមូលទិន្នន័យនាពេលបន្តបន្ទាប់ទៀត។

លទ្ធផលតាមស្ថាប័ន

ជំពូកនេះបង្ហាញទិន្នន័យពីគ្រឹះស្ថានឧត្តមសិក្សាដៃគូទាំង៥ ដោយរួមបញ្ចូលទិន្នន័យបរិមាណវិស័យរបស់ស្ថានប័នជាមួយនិងលទ្ធផលគុណវិស័យពីការស្ទង់មតិរបស់និស្សិត។ ការប្រមូលទិន្នន័យតាមគ្រឹះស្ថាននីមួយៗ ត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធស្របគ្នា ដែលរួមមាន៖ ទិន្នន័យការចុះឈ្មោះចូលរៀន, ការបន្តការសិក្សានិងការបញ្ចប់ការសិក្សា, សេវាគាំទ្រនិងហេដ្ឋារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបទពិសោធន៍របស់និស្សិត។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC)

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាគឺជាគ្រឹះស្ថានសាធារណៈឈានមុខគេខាងផ្នែកវិស្វកម្មដែលមានទីតាំងនៅក្រុងភ្នំពេញ ប្រទេសកម្ពុជា។ ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ វិទ្យាស្ថានបានទទួលនិស្សិតចុះឈ្មោះចូលរៀនចំនួន ៧៤៣២នាក់ ក្នុងនោះ ៦នាក់ត្រូវបានប្រកាសថាមានពិការភាព (0.08%)។

សូចនាករ	ចំនួន
ចំនួននិស្សិតចុះឈ្មោះសរុប	7,432
និស្សិតមានពិការភាពចុះឈ្មោះ	6 (0.08%)
ប្រភេទពិការភាព	កាយសម្បទា/ការធ្វើចលនា៖ 4 ចក្ខុ៖ 2
និស្សិតមានពិការភាពចូលថ្មី	1នាក់ ក្នុងចំណោម 2,086នាក់
និស្សិតមានពិការភាពដែលបានបញ្ចប់ការសិក្សា	3
និស្សិតមានពិការភាពដែលកំពុងបន្តការសិក្សាពីឆ្នាំមួយទៅឆ្នាំមួយ	3
បុគ្គលិកសិក្សា	398
បុគ្គលិករដ្ឋបាល	69
ថវិកាសរុប	632,000អឺរ៉ូ
អាហារូបករណ៍សម្រាប់និស្សិតមានពិការភាព	4,150អឺរ៉ូ (និស្សិត 6 នាក់)

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សូចនាករ	ចំនួន
ទិន្នន័យពីការផ្តល់ការសម្របសម្រួលជូនដល់និស្សិតពិការភាព	មិនបានរាយការណ៍
ទិន្នន័យស្តីពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល	មិនបានរាយការណ៍

តារាង៤. ITC: សូចនាករសំខាន់ៗ ឆ្នាំសិក្សា២០២៤២០២៥

និស្សិត ITC ដែលមានពិការភាពបានបញ្ចប់ការសិក្សា ចំនួន៣នាក់ ក្នុងចំណោម ៦នាក់ និងនិស្សិតពិការភាពកំពុងសិក្សាចំនួន៣នាក់, មិនមាននិស្សិតពិការភាពបោះបង់ការសិក្សា។ និស្សិតដែលមានពិការភាពទាំង៦នាក់បានទទួលជំនួយហិរញ្ញវត្ថុ។ ទោះជាយ៉ាងណា ITC មិនបានរាយការណ៍ទិន្នន័យអំពីសេវាកម្មសម្របសម្រួលនិស្សិតមានពិការភាព (accommodation delivery), ទិន្នន័យអំពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល (Digital Accessibility) ការប្រើប្រាស់សេវាគាំទ្រ (support service utilisation) ដែលមិនមែនជាជំនួយផ្នែកហិរញ្ញវត្ថុ ឬការបណ្តុះបណ្តាលបុគ្គលិកស្តីពីការយល់ដឹងអំពីពិការភាពនោះទេ។

ក្នុងការស្ទង់មតិស្តីពីការពេញចិត្តរបស់និស្សិតពិការភាពទៅលើសេវាកម្មគាំទ្ររបស់វិទ្យាស្ថាន (n=10) ITC បានទទួលពិន្ទុខ្ពស់ជាមធ្យមភាគទៅលើការពេញចិត្តជារួម (3.80/5), ការយល់ដឹងអំពីពិការភាពរបស់បុគ្គលិក (3.80/5) និងភាពងាយស្រួលក្នុងការចូលប្រើប្រាស់សម្ភារៈរូបវន្ត (3.70/5)។ ពិន្ទុស្តីពីការផ្តល់សេវាកម្មដោយមិនមានតម្លាភាព/អយុត្តិធម៌គឺជាពិន្ទុទាបបំផុតក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ (២.០០/៥) ដែលពិន្ទុទាបជាងគេមានន័យថាស្ថានភាពល្អជាង)។ នេះបង្ហាញថា និស្សិតនៅ ITC យល់ឃើញថា ពួកគេមិនទទួលរងការរើសអើងពីសិស្សដទៃឬស្ថាប័នឡើយ ឬការរើសអើងមានកម្រិតទាបបំផុត។

«វិទ្យាស្ថានរបស់ខ្ញុំមានភាពកក់ក្តៅចំពោះនិស្សិតមានពិការភាព ដោយគ្មានការរើសអើង»។

— និស្សិតមានពិការភាពផ្នែកកាយសម្បទា ITC

«ប្រសិនបើខ្ញុំអាចផ្លាស់ប្តូររឿងមួយបានខ្ញុំចង់ឱ្យមានការគាំទ្រហិរញ្ញវត្ថុពេញលេញដូចជាការលើកលែងថ្លៃសិក្សា 100%»។

— និស្សិតមានពិការភាពផ្នែកកាយសម្បទា ITC

រូបភាព២. សក្ខីកម្មរបស់និស្សិត – ITC

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)

សាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺជាសាកលវិទ្យាល័យសាធារណៈធំបំផុតនៅកម្ពុជាដែលមានចំនួននិស្សិត 29,098 នាក់ក្នុងឆ្នាំសិក្សា២០២៤-២០២៥។ សាកលវិទ្យាល័យមាននិស្សិតដែលមានពិការភាព: ១០៧នាក់ (0.37%) ដែលក្នុងនោះមាន៥៧ នាក់មានពិការភាពផ្នែកកាយសម្បទា/ចលនា ៣៤នាក់មានពិការភាពផ្នែកចក្ខុវិស័យ និង ១៦នាក់មានពិការភាពលើការស្តាប់។ RUPP បានទទួលនិស្សិតមានពិការភាពថ្មីចំនួន ៤១នាក់ ក្នុងចំណោមនិស្សិតឆ្នាំទី១ ដែលបានចុះឈ្មោះសរុបចំនួន ៩,៣៧៥ នាក់។

សូចនាករ	ចំនួន
ចំនួននិស្សិតចុះឈ្មោះសរុប	29,098
និស្សិតមានពិការភាពចុះឈ្មោះ	107 (0.37%)
ប្រភេទពិការភាព	កាយសម្បទា៖ 57 ចក្ខុ៖ 34 ការស្តាប់៖ 16
និស្សិតមានពិការភាពចូលថ្មី	41 ក្នុងចំណោម 9,375
និស្សិតមានពិការភាពបានបញ្ចប់ការសិក្សា	15
និស្សិតមានពិការភាពកំពុងបន្តការសិក្សា	43
និស្សិតមានពិការភាពដែលបោះបង់ការសិក្សា	5

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សូចនាករ	ចំនួន
បុគ្គលិកសិក្សា	592
បុគ្គលិករដ្ឋបាល	167 (បានបណ្តុះបណ្តាល 5នាក់)
វគ្គបណ្តុះបណ្តាលទាក់ទងជាមួយពិការភាព	1
ថវិកាសរុប	6,966,895អឺរ៉ូ
ថវិកាប្រើសម្រាប់សេវាកម្មសម្រាប់ជនពិការ	44,577អឺរ៉ូ
ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ	32,493អឺរ៉ូ
ថវិកាសម្រាប់ឧបករណ៍ឬបច្ចេកវិទ្យាជំនួយ	9,368អឺរ៉ូ
ថវិកាសម្រាប់ការបណ្តុះបណ្តាល	1,031អឺរ៉ូ
អាហារូបករណ៍សម្រាប់និស្សិតមានពិការភាព	1,685 អឺរ៉ូ(និស្សិត 113 នាក់)
និស្សិតមានពិការភាពចុះឈ្មោះនៅការិយាល័យគាំទ្រ	113
ការទំនាក់ទំនងទទួលសេវាដែលបានកត់ត្រា	243
គេហទំព័រដែលបានធ្វើសវនកម្ម (WCAG AA)	3 (អនុលោមតាមស្តង់ដារ 1)
ម៉ូឌុល LMS	184
ឯកសារសិក្សា	1,601

តារាង៥. RUPP: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥

RUPP ជាគ្រឹះស្ថានតែមួយគត់ក្នុងចំណោមគ្រឹះស្ថានផ្សេងទៀត ដែលបានរាយការណ៍ទិន្នន័យយ៉ាងទូលំទូលាយនៅក្នុងដែនសូចនាករភាគច្រើន។ RUPP មានការិយាល័យឧទ្ទិសសម្រាប់គាំទ្រនិស្សិតមានពិការភាព ដោយមាននិស្សិតចុះឈ្មោះចំនួន ១១៣នាក់ បានកត់ត្រាការទទួលសេវាចំនួន ២៤៣លើក និងបានបែងចែកថវិកាដាច់ដោយឡែកសម្រាប់សេវាកម្មគាំទ្រសិស្សមានពិការភាពចំនួន44,577អឺរ៉ូ,ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ32,493អឺរ៉ូ និងសម្រាប់ឧបករណ៍ឬបច្ចេកវិទ្យាជំនួយចំនួន 9,368អឺរ៉ូ។ ទោះបីជាមានហេដ្ឋារចនាសម្ព័ន្ធ និងធនធានគាំទ្រទាំងនេះក៏ដោយ ការស្ទង់មតិអំពីការពេញចិត្តរបស់និស្សិតពិការភាពទៅលើសេវាកម្មគាំទ្រ (n=7) បានបង្ហាញពីគម្លាតគួរឱ្យកត់សម្គាល់៖ ការយល់ដឹងអំពីសេវាគាំទ្រដែលមានស្រាប់ទទួលបានពិន្ទុ ២.៧១/៥ ដែលជាពិន្ទុទាបបំផុតក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំងអស់។ លទ្ធផលនេះបង្ហាញថា ទោះបីជាសេវាគាំទ្ររបស់ RUPP មានវិសាលភាពគួរសមក៏ដោយ ក៏ព័ត៌មានអំពីសេវាទាំងនេះប្រហែលជាមិនទាន់ត្រូវបានផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាពទៅដល់និស្សិតដែលត្រូវការសេវាទាំងនោះនៅឡើយ។ អត្រាការពេញចិត្តរបស់និស្សិតជារួមមានពិន្ទុ ៣.៤៣/៥។

«ប្រសិនបើខ្ញុំអាចផ្លាស់ប្តូររឿងមួយបាន ខ្ញុំចង់ឱ្យមានការបង្កើតការិយាល័យគាំទ្រ និងប្រឹក្សាជាក់លាក់សម្រាប់ជនពិការនៅក្នុងបរិវេណសាកលវិទ្យាល័យ» ។

— និស្សិតមានពិការភាព RUPP

«ខ្ញុំជានិស្សិតឆ្នាំទីមួយដែលមានបទពិសោធន៍ជាច្រើនក្នុងការធ្វើការផង និងរៀនផង ហើយខ្វះថវិកាសម្រាប់រៀនភាសាអង់គ្លេស» ។

— និស្សិតមានពិការភាព RUPP

រូបភាព៣. សក្ខីកម្មរបស់និស្សិត - RUPP

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សាកលវិទ្យាល័យវេស្ទើន (WU)

សាកលវិទ្យាល័យវេស្ទើនគឺជាគ្រឹះស្ថានឯកជននៅភ្នំពេញ ដែលមាននិស្សិតចុះឈ្មោះចូលរៀន ២៣៤៨ នាក់ ដែលក្នុងនោះនិស្សិតមានពិពិការភាពមានចំនួន ៦នាក់ (0.26%)។ ក្នុងចំណោមនិស្សិតមានពិការភាពទាំងនោះ មាន ២នាក់មានពិការភាពផ្នែកកាយសម្បទា/ចលនា, ២នាក់មានពិការភាពផ្នែកបញ្ញាស្មារតី/ការសិក្សា និង ២នាក់មានពិការភាពផ្នែកផ្លូវចិត្ត។ WU បានទទួលនិស្សិតមានពិការភាពចូលរៀនថ្មីចំនួន ៦នាក់ ក្នុងចំណោមនិស្សិតឆ្នាំទី១ សរុបចំនួន ២,៤៨២ នាក់។

សូចនាករ	ចំនួន
ចំនួននិស្សិតចុះឈ្មោះសរុប	2,348
និស្សិតមានពិការភាពចុះឈ្មោះ	6 (0.26%)
ប្រភេទពិការភាព	កាយសម្បទា៖ 2 បញ្ញាស្មារតី៖ 2 មានបញ្ហាផ្លូវចិត្ត៖ 2
និស្សិតមានពិការភាពកំពុងបន្តការសិក្សា	4
និស្សិតមានពិការភាពបោះបង់ការសិក្សា	2
អត្រាបោះបង់ការសិក្សាទូទៅ	33%
បុគ្គលិកសិក្សា	228
ថវិកាសរុប	3,986,627អឺរ៉ូ
ប្រព័ន្ធសម្របសម្រួលការផ្ដល់សេវាកម្មគាំទ្រនិស្សិពិការភាព	គ្មាន (បានបញ្ជាក់យ៉ាងច្បាស់)
ថវិកាជាក់លាក់សម្រាប់ពិការភាព	មិនបានរាយការណ៍

តារាង៦. WU: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥

WU បានបញ្ជាក់យ៉ាងច្បាស់ថា គ្រឹះស្ថានមិនមានប្រព័ន្ធសេវាកម្មសម្របសម្រួលនិស្សិតមានពិការភាព, មិនមានកញ្ចប់ថវិកាជាក់លាក់សម្រាប់គាំទ្រទៅដល់និស្សិតមានពិការភាព សេវាគាំទ្រការបណ្តុះបណ្តាលបុគ្គលិក ឬប្រព័ន្ធឌីជីថលសម្រាប់និស្សិតមានពិការភាពឡើយ។ អត្រាបោះបង់ការសិក្សាជារួម 33% គឺជាអត្រាខ្ពស់បំផុតក្នុងចំណោមគ្រឹះស្ថានដៃគូទាំងអស់ ហើយក្នុងចំណោមនិស្សិតមានពិការភាពចំនួន ៦នាក់ មាន ២នាក់ បានបោះបង់ការសិក្សា។

WU បានចូលរួមផ្តល់ចំនួនអ្នកឆ្លើយតបច្រើនជាងគេក្នុងការស្ទង់មតិនិស្សិត (n=16) ដែលឆ្លុះបញ្ចាំងពីការផ្សព្វផ្សាយ និងទំនាក់ទំនងជាមួយនិស្សិតយ៉ាងសកម្ម។ ទោះជាយ៉ាងណា WU ទទួលបានពិន្ទុទាបបំផុតពីការស្ទង់មិតិស្តីពីការពេញចិត្តជារួមរបស់និស្សិតទៅលើសេវាកម្មគាំទ្រនិស្សិតមានពិការភាពរបស់គ្រឹះស្ថាន (៣.៣៨/៥) និងការយល់ដឹងរបស់បុគ្គលិកអំពីតម្រូវការដែលពាក់ព័ន្ធនឹងពិការភាព (៣.២៥/៥)។ អ្នកឆ្លើយតបជាច្រើនបានលើកឡើងពីតម្រូវការកែលម្អភាពដើម្បីឲ្យមានភាពងាយស្រួលក្នុងការប្រើប្រាស់រចនាសម្ព័ន្ធរូបវន្ត ដូចជាអគារសិក្សានិងការគាំទ្របន្ថែមលើការសិក្សា។

«ខ្ញុំចង់ឱ្យស្ថាប័នកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តឱ្យងាយស្រួលប្រើប្រាស់ និងផ្តល់ការគាំទ្រការសិក្សាបន្ថែមដល់និស្សិតមានពិការភាព ដើម្បីឱ្យគ្រប់គ្នាអាចសិក្សាបានស្មើភាពគ្នា»។

— និស្សិតមានពិការភាព WU

«សូមកុំដាក់សម្ពាធច្រើនពេក ព្រោះខ្ញុំមិនសូវឆ្លាតដូចនិស្សិតទូទៅទេ»។

— និស្សិតមានពិការភាពផ្នែកការយល់ដឹង WU

រូបភាព ៤. សក្ខីកម្មរបស់និស្សិត – WU

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ (USEA)

សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍ គឺជាគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានទីតាំងនៅខេត្តសៀមរាប ហើយបានទទួលនិស្សិតចុះឈ្មោះចំនួន ១,៧០៨ នាក់ ក្នុងឆ្នាំសិក្សា ២០២៤–២០២៥។ USEA គឺជាស្ថាប័នតែមួយគត់ដែលមិនបានរាយការណ៍ទិន្នន័យស្តីពីការបែងចែកពិការភាព មិនមានទិន្នន័យអំពីចំនួននិស្សិតមានពិការភាពទិន្នន័យនិស្សិតមានពិការភាពដែលកំពុងបន្តការសិក្សាឬបញ្ចប់ការសិក្សា សេវាកម្មគាំទ្រនិស្សិតមានពិការភាព ការបណ្តុះបណ្តាលបុគ្គលិកទាក់ទងនឹងពិការភាព ឬទិន្នន័យអំពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថលឡើយ។ ទិន្នន័យដែលបានផ្តល់ មានតែចំនួននិស្សិតសរុប និងថវិកាសរុបរបស់ស្ថាប័ន (€1,000,000) ប៉ុណ្ណោះ។

«ខ្ញុំចង់ឱ្យសាលាបង្កើតគណៈកម្មការគាំទ្រពិសេសសម្រាប់និស្សិតមានពិការភាពផ្នែកចក្ខុ» ។

— និស្សិតមានពិការភាពផ្នែកគំហើញ USEA

រូបភាព៥. សក្ខីកម្មរបស់និស្សិត – USEA

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU)

សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ គឺជាគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានទីតាំងនៅរាជធានីភ្នំពេញ និងមាននិស្សិតចុះឈ្មោះចំនួន ២,២៤៤ នាក់ ដែលក្នុងនោះនិស្សិតមានពិការភាព (PWD) ដែលបានប្រកាសមានចំនួន ៧នាក់ (០.៣១%)។ និស្សិតមានពិការភាពទាំង ៧នាក់សុទ្ធតែមានពិការភាពផ្នែកកាយសម្បទា/ចលនា។ PPIU គឺជាស្ថាប័នតែមួយគត់ដែលបានរាយការណ៍អត្រានិស្សិតពិការភាពដែលកំពុងបន្តការសិក្សា និងបញ្ចប់ការសិក្សា៖ ដែលនិស្សិតទាំង៧នាក់ បានកំពុងបន្តការសិក្សា បន្តឡើងថ្នាក់ជាបន្តបន្ទាប់ពីឆ្នាំមួយទៅឆ្នាំមួយ។

សូចនាករ	ចំនួន
ចំនួននិស្សិតចុះឈ្មោះសរុប	2,244
និស្សិតមានពិការភាពចុះឈ្មោះ	7 (0.31%)
ប្រភេទពិការភាព	កាយសម្បទា/ការធ្វើចលនា៖ 7 (100%)
និស្សិតមានពិការភាពបញ្ចប់ការសិក្សា	7 (100%)
និស្សិតមានពិការភាពបន្តការសិក្សា	7 (100%)
និស្សិតមានពិការភាពបោះបង់ការសិក្សា	0
បុគ្គលិកសិក្សា	174
បុគ្គលិករដ្ឋបាល	56
ថវិកាសរុប	1,091,962 អឺរ៉ូ
អាហារូបករណ៍សម្រាប់និស្សិតមានពិការភាព	11,451អឺរ៉ូ
ថវិកាបណ្តុះបណ្តាលបុគ្គលិក	2,650អឺរ៉ូ
និស្សិតមានពិការភាពចុះឈ្មោះទទួលសេវាគាំទ្រ	7
និស្សិតប្រើប្រាស់ឧបករណ៍ឬបច្ចេកវិទ្យាជំនួយ	1
និស្សិតទទួលការគាំទ្រហិរញ្ញវត្ថុ	2

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សូចនាករ	ចំនួន
ម៉ូឌុល LMS ដែលបានធ្វើសវនកម្ម	1 (ងាយស្រួលចូលប្រើ)
ឯកសារសិក្សា	1,275

តារាង៧. PPIU: សូចនាករសំខាន់ៗ ឆ្នាំសិក្សា ២០២៤-២០២៥

PPIU បានបែងចែកថវិកាចំនួន 11,451អឺរ៉ូ ជាអាហារូបករណ៍សម្រាប់និស្សិតមានពិការភាព និង 2,650 អឺរ៉ូ សម្រាប់ការបណ្តុះបណ្តាលបុគ្គលិកស្តីពីបរិយាបន្ន។ និស្សិតមានពិការភាពទាំង៧នាក់ ត្រូវបានចុះឈ្មោះជាមួយការិយាល័យគាំទ្រ ប៉ុន្តែមានតែនិស្សិត ១នាក់ប៉ុណ្ណោះដែលបានប្រើប្រាស់បច្ចេកវិទ្យាជំនួយ ហើយនិស្សិត ២នាក់បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ។ PPIU ទទួលបានពិន្ទុខ្ពស់ជាងគេក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ តាមរយៈការស្ទង់មតិអំពីការពេញចិត្តរបស់និស្សិតមានពិការភាពទៅលើសេវាកម្មគាំទ្ររបស់គ្រឹះស្ថាន(n=4)៖ ការពេញចិត្តជារួម ៤.២៥/៥, ភាពងាយស្រួលក្នុងការប្រើប្រាស់សម្ភារៈរូបវន្ត ៤.២៥/៥, ការយល់ដឹងអំពីសេវាគាំទ្រ ៤.២៥/៥ និងការប្តេជ្ញាចិត្តរបស់គ្រឹះស្ថានក្នុងការគាំទ្រនិស្សិតមានពិការភាព ៤.២៥/៥។ ទោះបីជាទំហំសំណាកគំរូមានចំនួនតិច ដែលតម្រូវឱ្យមានការប្រុងប្រយ័ត្នក្នុងការបកស្រាយលទ្ធផលក៏ដោយ ក៏ពិន្ទុទាំងនេះមានកម្រិតខ្ពស់ និងមានភាពស្របគ្នានៅគ្រប់វិមាត្រទាំងអស់។

«««ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ហើយឥឡូវនេះកំពុងបន្តថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីពង្រឹងសមត្ថភាពការងាររបស់ខ្ញុំឱ្យកាន់តែប្រសើរ»។

— និស្សិតមានពិការភាពផ្នែករាងកាយ PPIU

«និស្សិតមានពិការភាពគួរតែទទួលបានអាហារូបករណ៍»។

— និស្សិត PPIU

តារាង៨. សក្ខីកម្មរបស់និស្សិត – PPIU

ការវិភាគបែបប្រៀបធៀប

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។



រូបភាព៦. ទិដ្ឋភាពសង្ខេបនៃមូលដ្ឋានគោល ២០២៤-២០២៥

ការប្រៀបធៀបរវាងស្ថាប័ន

ការបូកសរុបទិន្នន័យពីគ្រឹះស្ថានឧត្តមសិក្សាដែលចូលរួមចំនួន៥ បង្ហាញថា មាននិស្សិតសរុបចំនួន ៤២,៨៣០ នាក់ បានចុះឈ្មោះក្នុងឆ្នាំសិក្សា ២០២៤–២០២៥ ក្នុងនោះមាននិស្សិតចំនួន ១២៦នាក់ បានប្រកាសថាមានពិការភាព ដែលស្មើនឹង ០.២៩% នៃចំនួននិស្សិតសរុប។ គួរកត់សម្គាល់ថា របាយការណ៍នេះគ្រប់ដណ្ដប់លើគ្រឹះស្ថានឧត្តមសិក្សាចំនួន៥ប៉ុណ្ណោះ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៣២ របស់កម្ពុជា[1]។ ដូច្នេះ លទ្ធផលដែលបានបង្ហាញនេះ តំណាងឱ្យគំរូសំណាកមួយនៃស្ថានភាពទូទាំងប្រទេស មិនមែនជាការសិក្សាស្ទង់មតិដែលគ្រប់ដណ្ដប់លើវិស័យឧត្តមសិក្សាទាំងមូលនោះទេ។ សូម្បីតែក្នុងគំរូសំណាកនេះ អត្រាប្រកាសពិការភាព 0.29% មានកម្រិតទាបខ្លាំង បើប្រៀបធៀបទៅនឹងទិន្នន័យអន្តរជាតិ។ នៅសហភាពអឺរ៉ុប (EU) ក្នុងឆ្នាំ ២០២៤ ២៣.៩% នៃចំនួនប្រជាជនដែលមានអាយុ ១៦ ឆ្នាំឡើងទៅ ត្រូវបានរាយការណ៍ថា ការធ្វើសកម្មភាពប្រចាំថ្ងៃនៅមានកម្រិត។ លើសពីនេះ មានតែ ៣០.០% ប៉ុណ្ណោះ នៃយុវជនមានពិការភាព អាយុចាប់ពី ២៥–៣៤ ឆ្នាំ ដែលបានបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សា បើប្រៀបធៀបនឹង ៤៥.៩% នៃអ្នកដែលមិនមានពិការភាព[2]។ អត្រា ០.២៩% នេះ ទំនងជាឆ្លុះបញ្ចាំងពីការមិនប្រកាសអំពីស្ថានភាពពិការរបស់និស្សិត ដែលជាហេតុធ្វើឲ្យអត្រាពិការភាពមានកម្រិតទាប។ នេះបង្ហាញពីបញ្ហាប្រឈមជាប្រព័ន្ធដែលអាចកើតមានក្នុងការកំណត់អត្តសញ្ញាណនិស្សិតមានពិការភាព ការប្រមូលនិងគ្រប់គ្រងទិន្នន័យរបស់គ្រឹះស្ថាន និងកត្តានិស្សិតផ្ទាល់ក្នុងការមិនហ៊ានប្រកាសអំពីស្ថានភាពពិការរបស់ខ្លួន។

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

សូចនាករ	ITC	RUPP	WU	USEA	PPIU	សរុប/មធ្យម
ចំនួននិស្សិតចុះឈ្មោះសរុប	7,432	29,098	2,348	1,708	2,244	42,830
និស្សិតមានពិការភាពចុះឈ្មោះ	6	107	6	0	7	126
ភាគរយនិស្សិតមានពិការភាព	0.08%	0.37%	0.26%	0	0.31%	0.29%
និស្សិតមានពិការភាពបញ្ចប់ការសិក្សា	3	15	0	0	7	25
និស្សិតមានពិការភាពបោះបង់ការសិក្សា	0	5	2	0	0	7
និស្សិតមានពិការភាពបន្តការសិក្សា	3	43	4	0	7	57
ការពេញចិត្តរបស់និស្សិតពិការភាពទៅលើសេវាកម្មគាំទ្រ (1-5)	3.80	3.43	3.38	3.67	4.25	3.60
ការយល់ដឹងអំពីសេវាកម្មគាំទ្រ	3.50	2.71	3.00	3.33	4.25	3.23
ការយល់ដឹងរបស់បុគ្គលិកអំពីពិការភាព	3.80	3.57	3.25	3.67	4.00	3.55

តារាង១០. ការប្រៀបធៀបរវាងស្ថាប័ន៖ សូចនាករសំខាន់ៗ

ពិការភាពផ្នែកកាយសម្បទា/ការធ្វើចលនា មានចំនួន ៥៦% នៃពិការភាពដែលបានប្រកាសសរុបទាំងអស់ (៧០ នាក់ ក្នុងចំណោម ១២៦ នាក់) បន្ទាប់មកគឺពិការភាពផ្នែកចក្ខុវិស័យ (២៩% ឬ ៣៦នាក់) និងពិការភាពផ្នែកការស្តាប់ (១៣% ឬ ១៦នាក់)។ ពិការភាពផ្នែកបញ្ញាស្មារតី- ផ្លូវចិត្ត និងប្រភេទពិការភាពផ្សេងៗទៀត មានចំនួនតិចជាងទិន្នន័យដែលរាយការណ៍ ដែលនេះទំនងជាឆ្លុះបញ្ចាំងទាំងលំនាំនៃការប្រកាសពិការភាពនិងការមើលឃើញជាក់ស្តែងនូវប្រភេទពិការភាពនីមួយៗ។



រូបភាព៧. ការចុះឈ្មោះនិស្សិត និងពិការភាពដែលបានប្រកាសតាមគ្រឹះស្ថានឧត្តមសិក្សា ឆ្នាំសិក្សា២០២៤-២០២៥

ការរកឃើញដែលគួរឱ្យកត់សម្គាល់បំផុតពីការប្រៀបធៀបទិន្នន័យរវាងស្ថាប័នគឺភាពមិនពេញលេញនៃទិន្នន័យដែលផ្តល់ដោយគ្រឹះស្ថាននីមួយៗ។ RUPP បានរាយការណ៍ទិន្នន័យស្ទើរតែគ្រប់ដែនសូចនាករ។ PPIU បានរាយការណ៍ទិន្នន័យភាគច្រើនក្នុងដែនសូចនាករ។ ITC បានរាយការណ៍ទិន្នន័យអំពីការចុះឈ្មោះចូលរៀនរបស់និស្សិត ការគាំទ្រនិស្សិតឱ្យបន្តការសិក្សា និងថវិកាគាំទ្រ។ WU បានរាយការណ៍ទិន្នន័យអំពីការចុះឈ្មោះចូលរៀនរបស់និស្សិត និងការគាំទ្រនិស្សិតឱ្យបន្តការសិក្សា។ ចំណែក USEA បានរាយការណ៍តែចំនួននិស្សិតសរុប និងថវិកាប៉ុណ្ណោះ។

ភាពមិនពេញលេញនេះផ្ទាល់គឺជាលទ្ធផលសំខាន់បំផុតនៃមូលដ្ឋានគោលទិន្នន័យគោលនេះ (baseline) ព្រោះវាបង្ហាញពីចំណុចដែលប្រព័ន្ធទិន្នន័យរបស់គ្រឹះស្ថាននីមួយៗខ្វះខាតនិងត្រូវការការពង្រឹងបន្ថែម

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

មុនពេលអាចធ្វើការវិភាគនិន្នាការប្រកបដោយអត្ថន័យ និងមានភាពជឿជាក់បាន។

ឧបសគ្គនានាក្នុការប្រើប្រាស់សេវាកម្មគាំទ្ររបស់គ្រឹះស្ថាន៖ ការរួមបញ្ចូលគ្នាទិន្នន័យបរិមាណវិស័យ និងគុណវិស័យ

ការផ្ទៀងផ្ទាត់ទិន្នន័យបរិមាណវិស័យនិងទិន្នន័យគុណវិស័យតាមបែបត្រីកោណមាត្រ(Triangulating quantitative and qualitative data) បានបង្ហាញឱ្យឃើញនូវចំណុចដែលស្របគ្នា និងចំណុចដែលមានភាពខុសគ្នាមួយចំនួន ៖

- **គម្លាតនៃការការផ្តល់សេវាកម្មសម្របសម្រួលដល់និស្សិតមានពិការភាព (Accommodation Gap)**៖ មិនមានគ្រឹះស្ថានឧត្តមសិក្សាណាមួយរាយការណ៍ជាផ្លូវការអំពីប្រព័ន្ធតាមដានសេវាកម្មសម្របសម្រួលដល់និស្សិតមានពិការភាពឡើយ ហើយ WU បានបញ្ជាក់យ៉ាងច្បាស់ថាខ្លួនមិនមានប្រព័ន្ធផ្តល់សេវាកម្មសម្របសម្រួលដល់និស្សិតមានពិការភាពទេ។ ក្នុងការស្ទង់មតិ 28% នៃអ្នកឆ្លើយតប បានលើកឡើងពីអគាររូបវន្តដែលមិនមានភាពងាយស្រួលក្នុងការចូលប្រើប្រាស់ និង 13% បានលើកឡើងពីកង្វះខាតសេវាកម្មសម្របសម្រួលការប្រឡងដល់និស្សិតមានពិការភាព ដែលលទ្ធផលនេះបញ្ជាក់ថា កង្វះខាតទិន្នន័យ គឺឆ្លុះបញ្ចាំងពីការខ្វះខាតប្រព័ន្ធរៀបចំ និងប្រព័ន្ធគាំទ្រជាក់ស្តែង។

- **ភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល (Digital Accessibility)**៖ មានតែ RUPP និង PPIU ប៉ុណ្ណោះដែលបានរាយការណ៍ទិន្នន័យមួយផ្នែកស្តីពីភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល។ មិនមានគ្រឹះស្ថានណាមួយបានអនុវត្តការធ្វើសវនកម្ម **WCAG** យ៉ាងទូលំទូលាយនៅឡើយទេ។ ទោះជាយ៉ាងណា និស្សិតបានវាយតម្លៃការចូលប្រើប្រាស់សម្ភារៈឌីជីថលក្នុងកម្រិតគួរសម(៣.៧០/៥) ដែលបង្ហាញថា គម្លាតនេះកើតមានច្រើននៅត្រង់កង្វះខាតការធ្វើសវនកម្មជាប្រព័ន្ធជាជាងបញ្ហាគុណភាពនៃសម្ភារៈឌីជីថល។
- **ភាពផ្ទុយគ្នានៃសេវាគាំទ្រ (Support Services Paradox)**៖ RUPP ជាគ្រឹះស្ថានមានការិយាល័យឧទ្ទិសសម្រាប់គាំទ្រនិស្សិតមានពិការភាពតែមួយគត់ក្នុងចំណោមគ្រឹះស្ថានទាំងអស់ ដោយមាននិស្សិតមានពិការភាពចុះឈ្មោះចំនួន ១១៣នាក់ និងបានកត់ត្រាការទទួលសេវាកម្មចំនួន ២៤៣ លើក។ ទោះជាយ៉ាងណា និស្សិតនៅ RUPP បានផ្តល់ពិន្ទុទាបបំផុតចំពោះ ការយល់ដឹងអំពីសេវាគាំទ្រ (២.៧១/៥) ដែលបង្ហាញថា សេវាគាំទ្រមានស្រាប់ ប៉ុន្តែការផ្សព្វផ្សាយ និងការទំនាក់ទំនងអំពីសេវាទាំងនេះនៅមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់។ នេះគឺជាការរកឃើញដ៏សំខាន់មួយ៖ ការវិនិយោគលើសេវាគាំទ្រ ដោយមិនវិនិយោគលើការធ្វើឱ្យសេវាកម្មទាំងនោះមានភាពលេចធ្លោ និងងាយស្រួលឱ្យនិស្សិតស្គាល់ អាចឲ្យសេវាកម្មគាំទ្រមិនមានប្រសិទ្ធភាព និងមានផលប៉ះពាល់ដល់សេវាកម្មទាំងនោះ។
- **ភាពលេចធ្លោនៃការគាំទ្រផ្នែកហិរញ្ញវត្ថុ (Financial Support Dominance):** អាហារូបករណ៍ គឺជាទម្រង់នៃការគាំទ្រហិរញ្ញវត្ថុមួយដែលស្ថាប័នផ្តល់ជូនញឹកញាប់ជាងគេ និងជាទម្រង់គាំទ្រដែលនិស្សិតប្រើប្រាស់ញឹកញាប់ជាងគេផងដែរ ដោយមាននិស្សិតចំនួន ៥៥% បានទទួលឬប្រើប្រាស់ការគាំទ្រប្រភេទនេះ។ ទោះជាយ៉ាងណា ចម្លើយក្នុងសំណួរបើកចំហរបស់និស្សិតបានបង្ហាញថា តម្រូវការរបស់ពួកគេមិនត្រឹមតែជាជំនួយផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែរួមមាន អគាររូបវន្តដែលមានភាពងាយស្រួលក្នុងការចូលប្រើប្រាស់ ការប្រឹក្សាយោបល់ បច្ចេកវិទ្យាឬឧបករណ៍ជំនួយ និងការផ្លាស់ប្តូរឥរិយាបថ និងទស្សនៈរបស់បុគ្គលិកអប់រំទៅកាន់និស្សិតមានពិការភាពផងដែរ។

ការប្រៀបធៀបនឹងក្របខ័ណ្ឌជាតិ និងអន្តរជាតិ

គោលនយោបាយកម្ពុជាស្តីពីបរិយាបន្នអប់រំ(ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨) និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ផ្តោតសំខាន់ទៅលើការធានាឲ្យបាននូវការទទួលបានការអប់រំប្រកបដោយសមធម៌សម្រាប់អ្នកសិក្សាទាំងអស់ រួមទាំងអ្នកមានពិការភាពផងដែរ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (CRPD) ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ ២០១២ តម្រូវឲ្យស្ថាប័នរដ្ឋទាំងអស់ធានាឲ្យមានការអប់រំបរិយាបន្ននៅគ្រប់កម្រិតសិក្សាទាំងអស់។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (SDG 4:Quality Education) ៖ ធានាការអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ ប្រកបដោយគុណភាព និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដោយចំណុចដៅទី ៤.៥ ផ្តោតជាពិសេសលើពិការភាព។

បើប្រៀបធៀបជាមួយក្របខណ្ឌទាំងនេះ ទិន្នន័យមូលដ្ឋានបានបង្ហាញពីគម្លាតអនុវត្តដ៏សំខាន់មួយ។ ទោះបីជាគោលនយោបាយជាតិបានប្តេជ្ញាចិត្តចំពោះការអប់រំដែលប្រកបដោយបរិយាបន្នក៏ដោយ

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

ទិន្នន័យរបស់គ្រឹះស្ថានឧត្តមសិក្សាបានបង្ហាញថា គ្រឹះស្ថានឧត្តមសិក្សាភាគច្រើននៅខ្វះប្រព័ន្ធមូលដ្ឋានសម្រាប់ កំណត់អត្តសញ្ញាណ តាមដាន និងគាំទ្រនិស្សិតមានពិការភាព។ គ្រឹះស្ថានភាគច្រើនមិនទាន់នូវសេវាកម្មសម្របសម្រួលនិស្សិតពិការភាព ការធ្វើសវនកម្មទៅលើភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល ការបែងចែកថវិកាដាច់ដោយឡែកសម្រាប់ការងារពាក់ព័ន្ធនឹងពិការភាព និងការបណ្តុះបណ្តាលបុគ្គលិកឲ្យយល់ដឹងអំពីពិការភាព នៅឡើយ។ ក្របខណ្ឌ និងគោលការណ៍ទាំងនោះមានរួចហើយ ប៉ុន្តែអ្វីដែលនៅខ្វះខាត គឺហេដ្ឋារចនាសម្ព័ន្ធស្ថាប័នដែលចាំបាច់សម្រាប់អនុវត្តក្របខណ្ឌ និងគោលការណ៍ទាំងនោះឲ្យមានប្រសិទ្ធភាព។

ផែនការមេអាស៊ានស្តីពីការលើកកម្ពស់សិទ្ធិជនមានពិការភាព ឆ្នាំ២០២៥ (ASEAN Enabling Masterplan 2025) បានអំពាវនាវឲ្យស្ថាប័នរដ្ឋនានាធានាឲ្យមានបរិយាកាសសិក្សាប្រកបដោយបរិយាបន្នសម្រាប់ជនមានពិការភាព [1]។ ទិន្នន័យបង្ហាញថា គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជានៅមិនទាន់ឈានដល់ស្តង់ដារនេះនៅឡើយទេ។ ទោះជាយ៉ាងណា ការអនុវត្តនៅក្នុងគ្រឹះស្ថានមួយចំនួន ដូចជាការិយាល័យឧទ្ទិសគាំទ្ររបស់ RUPP និង អត្រាគាំទ្រនិស្សិតឲ្យបន្តការសិក្សា ១០០% របស់ PPIU បានបង្ហាញថា ការរីកចម្រើនអាចសម្រេចបាន ទោះបីធនធានដែលមានស្រាប់នៅមានកម្រិតក៏ដោយ។

ការឆ្លើយតបរបស់គម្រោង GAIN

លទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍ទិន្នន័យមូលដ្ឋាននេះ បានបញ្ជាក់ពីតម្រូវការចាំបាច់សម្រាប់ការចូលរួមនានាដែលគម្រោង GAIN នឹងរៀបចំឡើងដើម្បីអនុវត្ត។ ជំពូកនេះរៀបរាប់អំពីរបៀបដែលគម្រោងនឹងឆ្លើយតបដោយផ្ទាល់ទៅនឹងគម្លាតដែលបានរកឃើញតាមរយៈទិន្នន័យដែលប្រមូលបាន។



រូបភាព៨. ការឆ្លើយតបរបស់គម្រោង GAIN

វិធីសាស្ត្រកិច្ចសហការចតុកោណ (The Quadruple-Helix Approach)

គំរូកិច្ចសហការចតុកោណរបស់គម្រោង GAIN (GAIN's quadruple-helix model) ធានាថាបរិយាបន្នត្រូវបានយកមកពិចារនានិងដោះស្រាយពីទិសដៅចំនួនបួនក្នុងពេលដំណាលគ្នា៖

- **រដ្ឋាភិបាល(ចតុកោណទី១)**៖ តាមរយៈយន្តការកំណែទម្រង់គោលនយោបាយដែលដឹកនាំដោយ ក្រសួងអប់រំ យុវជន និងកីឡា Special Interest Groups (SIGs) និង ឧបករណ៍សម្រាប់ផ្ទៀងផ្ទាត់ការអនុលោមតាមគោលនយោបាយ (Policy Conformity Toolkit) (WP1 ដល់ WP2)។ ឧបករណ៍វិភាគទិន្នន័យ (Data Analysis Tool) ជាឧបករណ៍ដែលគ្រប់គ្រងដំណើរការដោយរដ្ឋាភិបាល ដែលធានាថា រាល់ភស្តុតាងជាក់ស្តែងនិងទិន្នន័យនានា ត្រូវបានបញ្ចូលទៅក្នុងការរៀបចំផែនការថ្នាក់ជាតិ។
- **វិស័យសិក្សា/សាកលវិទ្យាល័យ (ចតុកោណទី២)**៖ តាមរយៈការកសាងសមត្ថភាពស្ថាប័ន, ការ

Co-funded by
the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

បង្កើតបណ្ណុំកម្មវិធីរួមអំពីបរិយាបន្ន (Inclusivity Engagement Portfolio) ដែលរួមមានម៉ូឌុល OER ចំនួន ១០ និង ២០ ECTS, រៀបចំសិក្ខាសាលាកសាងសមត្ថភាព (ធ្វើឡើង២ដង ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា ដោយកំណត់អ្នកចូលរួមយ៉ាងតិចប្រមាណ ២៥០នាក់) និងការបង្កើតមជ្ឈមណ្ឌលបរិយាបន្ន (Institutional Inclusivity Centers – IICs) ដែលបំពាក់ដោយឧបករណ៍បច្ចេកទេសសម្រាប់ជំនួយដល់និស្សិតមានពិការភាព ដូចជា Disability Access Seats នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាដៃគូនីមួយៗ (WP3)។

- **វិស័យឯកជន (ចត្កោណទី៣)**៖ តាមរយៈភាពជាដៃគូជាមួយវិស័យឧស្សាហកម្ម សេវាកម្មស្វែងរកការងារ និង គំនិតផ្តួចផ្តើមលើកកម្ពស់ភាពងាយស្រួលក្នុងការចូលបម្រើការងារសម្រាប់និស្សិតដែលបញ្ចប់ការសិក្សាថ្មីៗ(WP4)។
- **សង្គមស៊ីវិល (ចត្កោណទី៤)**៖ តាមរយៈយុទ្ធនាការលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ សកម្មភាពរួមគ្នាដើម្បីជំរុញបរិយាបន្ន និងបណ្តាញកិច្ចសន្ទនាគោលនយោបាយជាមួយសង្គមស៊ីវិល និងអង្គការជនពិការនានា (Disabled People's Organisations – DPOs) (WP5)។

ការរួមចំណែករបស់គម្រោងក្នុងពេលបច្ចុប្បន្ន និងអនាគត

ការរួមចំណែកផ្សេងៗរបស់គម្រោង GAIN ដែលឆ្លើយតបដោយផ្ទាល់ចំពោះគម្លាតផ្សេងៗដែលបានកំណត់ក្នុងរបាយការណ៍នេះ៖

- **គម្លាតនៃការបណ្តុះបណ្តាលបុគ្គលិក**→បណ្ណុំកម្មវិធីរួមអំពីបរិយាបន្ន **(Inclusivity Engagement Portfolio)** (D3.2) កំពុងនឹងត្រូវបានតាក់តែងឡើង ។ សំណុំនេះរួមមាន **ម៉ូ**ឌុលចំនួន ១០ (៨ សម្រាប់បុគ្គលិកសិក្សានិងបុគ្គលិកគ្រប់គ្រង និង ២ សម្រាប់បុគ្គលិករដ្ឋបាល) ដែលមានចំនួនសរុប ២០ ECTS និងត្រូវបានផ្តល់ជូនជាពីរភាសា តាមរយៈវេទិកាសហការគម្រោង GAIN (GAIN Collaboration Platform)។
  ម៉ូឌុលទាំងនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការរកឃើញដែលបង្ហាញថា មិនទាន់មានបុគ្គលិកសិក្សាណាម្នាក់បានទទួលការបណ្តុះបណ្តាលជាផ្លូវការអំពីរបៀបប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់និស្សិតមានពិការភាពឬការយល់ដឹងអំពីពិការភាពនៅឡើយទេ។
- **គម្លាតផ្នែកសេវាគាំទ្រ**→គ្រឹះស្ថានឧត្តមសិក្សានីមួយៗនឹងបង្កើតមជ្ឈមណ្ឌលបរិយាបន្ន (Institutional Inclusivity Center – IIC) **ដែល**បំពាក់ដោយឧបករណ៍បច្ចេកទេសសម្រាប់ជំនួយដល់និស្សិតមានពិការភាព (Disability Access Seats)។ មជ្ឈមណ្ឌលទាំងនេះនឹងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលមានលក្ខណៈផ្លូវការ ដែលតាមទិន្នន័យបានបង្ហាញថាភាគច្រើននៅមិនទាន់មាននៅក្នុងគ្រឹះស្ថាននីមួយៗនៅឡើយទេ។
- **គម្លាតផ្នែកទិន្នន័យ និងវេទិកាចូលរួម** → វេទិកាសហការគម្រោងGAIN (**GAIN Collaboration Platform**) (platform.gainproject.eu) ផ្ទុកទៅដោយឧបករណ៍វិភាគទិន្នន័យ (Data Analysis Tool), ម៉ូឌុល OER និងធនធានសម្រាប់កិច្ចសហការ ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល សម្រាប់ការចែករំលែកចំណេះដឹងដែលមានពីរភាសាអាចឲ្យអ្នកចូលប្រើប្រាស់បានងាយស្រួល។
- **បង្កើនសមត្ថភាពស្ថាប័ន** → សិក្ខាសាលាកសាងសមត្ថភាពចំនួន ១០ (២លើកសម្រាប់ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា) នឹងប្រើប្រាស់ម៉ូឌុល OER ជាខ្លឹមសារសម្រាប់ការបណ្តុះបណ្តាល កំណត់អ្នកចូលរួមយ៉ាងតិច ២៥០នាក់ នៅទូទាំងស្ថាប័នដៃគូទាំងអស់។
- **គម្លាតនៃការអនុវត្តគោលនយោបាយ**→ឧបករណ៍សម្រាប់ផ្ទៀងផ្ទាត់ការអនុលោមតាមគោលនយោបាយ (Policy Conformity Toolkit) អាចឲ្យគ្រឹះស្ថានឧត្តមសិក្សានីមួយៗវាយតម្លៃ និងកែលម្អគោលនយោបាយរបស់ខ្លួន ដោយប្រៀបធៀបជាមួយស្តង់ដារបរិយាបន្ន ដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងគម្លាតនៃការអនុវត្តគោលនយោបាយដែលបានរកឃើញនៅក្នុងរបាយការណ៍នេះ។

និរន្តរភាពក្រោយបញ្ចប់គម្រោង

ឧបករណ៍វិភាគទិន្នន័យ (Data Analysis Tool) ត្រូវបានរៀបចំឡើងដោយផ្តោតលើនិរន្តរភាពរយៈពេលវែង។ ឧបករណ៍នេះនឹងត្រូវបានគ្រប់គ្រងប្រព័ន្ធបច្ចេកទេសដោយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងគ្រប់គ្រងទិន្នន័យដោយ ក្រសួងអប់រំ យុវជន និងកីឡា នឹងប្រើប្រាស់ឧបករណ៍នេះដើម្បីវាស់វែងគោលនយោបាយ។ ឧបករណ៍នេះនឹងនៅតែបន្តប្រមូល វិភាគ និងរាយការណ៍ទិន្នន័យ ទោះបីជាគម្រោងដែលមានរយៈពេល ៤៨ ខែ ត្រូវបានបញ្ចប់ក៏ដោយ។

វដ្តនៃការប្រមូលទិន្នន័យប្រចាំឆ្នាំនឹងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ដែលអាចឲ្យក្រសួងអប់រំ យុវជន និងកីឡា តាមដានវឌ្ឍនភាព វាយតម្លៃផលប៉ះពាល់នៃគោលនយោបាយ

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។

និងធ្វើសេចក្តីសម្រេចដោយផ្អែកលើព័ត៌មាន និងភស្តុតាងដែលទទួលបានពីរបាយការណ៍។ វិសាលភាពនៃការប្រើប្រាស់ឧបករណ៍នេះនឹងត្រូវបានពង្រីកជាបន្តបន្ទាប់ ដើម្បីរួមបញ្ចូលបន្ថែមនូវគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗទៀតដែលមិនមែនជាសមាជិកគម្រោង ដើម្បីគាំទ្រដល់ការរៀបចំផែនការ និងការអភិវឌ្ឍគោលនយោបាយនៅកម្រិតជាតិ។

សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

របាយការណ៍ប្រចាំឆ្នាំលើកដំបូងនៃឧបករណ៍វិភាគទិន្នន័យរបស់គម្រោង GAIN បានបង្កើតនូវទិន្នន័យមូលដ្ឋានដំបូងសម្រាប់ការវាស់វែងបរិយាបន្នជនពិការភាពនៅក្នុងវិស័យអប់រំឧត្តមសិក្សាកម្ពុជា ដោយផ្អែកលើទិន្នន័យពីគ្រឹះស្ថាននានា។ រូបភាពដែលទទួលបាន បង្ហាញថា វិស័យនេះកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូង ប៉ុន្តែមានការរីកចម្រើននៅក្នុងដំណើរឆ្ពោះទៅរកការធ្វើឲ្យបរិយាបន្នអប់រំកាន់តែប្រសើរ។

ចំណុចសំខាន់បំផុតដែលបានរកឃើញមិនមែនជាតួលេខណាមួយតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាលំនាំទិន្នន័យដែលមិនទាន់ត្រូវបានវាស់វែងឬប្រមូលជាប្រព័ន្ធ។ សេវាកម្មសម្របសម្រួលនិស្សិតមានពិការភាព (Accommodation) ការផ្តល់សេវាកម្មអប់រំ (Delivery) ភាពងាយស្រួលក្នុងការចូលប្រើប្រាស់ប្រព័ន្ធឌីជីថល (Digital Accessibility) សេវាគាំទ្រផ្លូវការ និងការបណ្តុះបណ្តាលបុគ្គលិកឲ្យយល់ដឹងពីពិការភាព នៅតែមិនទាន់ត្រូវបានតាមដានឬវាស់វែងឲ្យស៊ីជម្រៅនៅឡើយនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាភាគច្រើន។ គម្លាតទាំងនេះមិនមែនជាការចំនុចខ្វះខាតរបស់របាយការណ៍នេះទេ ប៉ុន្តែវាគឺជាទិន្នន័យមូលដ្ឋានគោល (Baseline) សម្រាប់វាស់វែងនិងកែលម្អ និងជាមូលដ្ឋានគោលដើម្បីប្រៀបធៀបទិន្នន័យនាពេលអនាគត។

ទន្ទឹមនឹងនេះ ទិន្នន័យក៏បង្ហាញពីចំណុចខ្លាំងជាក់ស្តែង ដែលអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍបន្ថែម៖

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) គឺជាគ្រឹះស្ថានតែមួយគត់ដែលមានការិយាល័យឧទ្ទិសគាំទ្រនិស្សិតមានពិការភាពក្នុងចំណោមគ្រឹះស្ថានផ្សេងទៀតដែលជាសមាជិកគម្រោង ដោយមាននិស្សិតចុះឈ្មោះចំនួន ១១៣នាក់ និងមានការទទួលសេវាគាំទ្រចំនួន ២៤៣លើក។ នេះអាចជាគំរូសម្រាប់គ្រឹះស្ថានឧត្តមសិក្សាផ្សេងទៀត។
- សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ (PPIU) សម្រេចបានអត្រា ១០០% នៃអត្រានិស្សិតមានពិការភាពបន្តការសិក្សានិងបញ្ចប់ការសិក្សា ដែលបង្ហាញពីបរិយាបន្នអប់រំពេញលេញដែលអាចសម្រេចបានទោះបីជនជានដែលមានស្រាប់នៅមានកម្រិតក៏ដោយ។
- និស្សិតបានរាយការណ៍ពីកម្រិតនៃការពេញចិត្តសេវាកម្មជារួមក្នុងកម្រិតមធ្យម (៣.៦០/៥) និងយល់ឃើញថា សេវាកម្មដែលទទួលបានមានភាពមិនស្មើគ្នាឬមិនមានតម្លាភាព ក្នុងកម្រិតទាប (២.៤៥/៥)។ ទិន្នន័យនេះផ្តល់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍបន្ថែម។។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូននិស្សិតនិងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ ទោះជាយ៉ាងណា ហេដ្ឋារចនាសម្ព័ន្ធនិងយន្តការដែលមានសម្រាប់ការផ្តល់អាហារូបករណ៍ គួរអាចពង្រីកទៅជាទម្រង់ផ្សេងៗទៀតនៃសេវានិងការគាំទ្រ។

Co-funded by the European Union
ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។



រូបភាព៩. លទ្ធផលស្ទង់មតិពីការពេញចិត្តរបស់និស្សិតតាមស្ថាប័ន ឆ្នាំសិក្សា ២០២៤-២០២៥

ជំហានបន្ទាប់

របាយការណ៍នេះ គឺជារបាយការណ៍ដំបូងក្នុងចំណោមរបាយការណ៍ប្រចាំឆ្នាំចំនួន ៤ ដែលនឹងត្រូវរៀបចំ និងចេញផ្សាយជាបន្តបន្ទាប់។ របាយការណ៍ប្រចាំឆ្នាំបន្ទាប់ នឹងគ្រប់ដណ្ដប់លើឆ្នាំសិក្សា ២០២៥–២០២៦ នឹងចេញផ្សាយនៅឆ្នាំ២០២៧។ នៅពេលឈានដល់ការរៀបចំរបាយការណ៍ជាបន្តបន្ទាប់ ការចូលរួមសំខាន់ៗមួយចំនួនរបស់គម្រោង GAIN នឹងត្រូវបានអនុវត្តរួចរាល់ដែលរួមមាន ការបណ្ដុះបណ្ដាលបុគ្គលិក ស្ដីអំពីម៉ូឌុលដែលបានបង្កើតឡើង សិក្ខាសាលាកសាងសមត្ថភាព និងការបង្កើតមជ្ឈមណ្ឌលបរិយាបន្ន។ ការរួមចំណែកទាំងអស់នេះនឹងអាចឲ្យរបាយការណ៍វាយតម្លៃបានថា តើសកម្មភាពរបស់គម្រោងបានរួមចំណែកកម្រិតក្នុងធ្វើឲ្យប្រសើរឡើងនៃប្រព័ន្ធប្រមូលទិន្នន័យនៅកម្រិតស្ថាប័ន សេវាគាំទ្រ និងបទពិសោធន៍របស់និស្សិត។

ទិន្នន័យនៅក្នុងឧបករណ៍វិភាគទិន្នន័យគម្រោង GAIN (GAIN Data Analysis Tool) នឹងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ឧបករណ៍នេះអាចអ្នកចូលប្រើប្រាស់បានតាមរយៈវេទិកាសហការគម្រោង GAIN (GAIN Collaboration Platform) ដោយអ្នកប្រើប្រាស់អាចចូលទៅកាន់ទិន្នន័យចុងក្រោយបំផុតរបស់ ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានឧត្តមសិក្សានានា អ្នកស្រាវជ្រាវ ព្រមទាំងសហគមន៍អន្តរជាតិ។

ស្ថាប័នដៃគូគម្រោង GAIN នៅតែប្ដេជ្ញាចិត្ត ធ្វើឲ្យចក្ខុវិស័យនៃប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា ភាពងាយស្រួលក្នុងការចូលប្រើប្រាស់បាន មានបរិយាបន្ន និងមានការគាំទ្រច្រើនផ្អែកតាមតម្រូវការរបស់និស្សិតមានពីការភាពទាំងអស់។ របាយការណ៍នេះគឺជាជំហានដំបូងឆ្ពោះទៅរកអនាគតដោយផ្អែកលើភស្តុតាងជាក់ស្ដែង និងទិន្នន័យជាក់លាក់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍការអប់រំឧត្តមសិក្សាកម្ពុជាប្រកបដោយបរិយាបន្ន។

Co-funded by the European Union

ទស្សនៈនិងមតិយោបល់ដែលបានបង្ហាញជារបស់អ្នកនិពន្ធប៉ុណ្ណោះហើយមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬទីភ្នាក់ងារប្រតិបត្តិអឺរ៉ុបសម្រាប់ការអប់រំ និងវប្បធម៌ (EACEA) ឡើយ។ សហភាពអឺរ៉ុប និង EACEA មិនទទួលខុសត្រូវចំពោះទស្សនៈ និងមតិទាំងនេះទេ។